**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ : ០៨៩ ប្រក.កសក

# ប្រកាស

## ស្តីពី

## ផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងព្រៃសម្បទាន
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សម្រេច

**ប្រការ ១ :** ហាមឃាត់ការប្រមូលផល អនុផលព្រៃឈើនៅក្នុងព្រៃធម្មជាតិនៃព្រៃបំរុងទុកអចិន្ត្រៃយ៍គ្រប់ប្រភេទ ដូចមានកំណត់ខាងក្រោម :

១- ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ

២- ប្រភេទឈើដែលមានដោយកម្រ

៣- ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី

៤- ដើមឈើផ្តល់ជ័រមានតំលៃ ។

ការប្រមូលផល អនុផលព្រៃឈើក្នុងកថាខ័ណ្ឌទី ១ ខាងលើ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ២ :** ប្រភេទឈើដែលអនុញ្ញាតឱ្យកាប់រំលំក្នុងដំណើរការប្រមូលផលក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវបានចាត់ថ្នាក់តាមលំដាប់ថ្នាក់ និង កំណត់អង្កត់ផ្ចិតអប្បបរមាវាស់នៅត្រង់គល់កំពស់ ១,៣០ម ពីដី ឬកំពស់ ០,៣០ម លើឫសព្រីង ស្របតាមការលូតលាស់ និងបច្ចេកទេសរុក្ខវប្បកម្មសំរាប់ប្រភេទឈើនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី I នៃប្រកាសនេះ ។

**ប្រការ ៣ :** ចំពោះកូនឈើដែលមានទំហំអង្កត់ផ្ចិតក្រោម ៣០សម អាចអនុញ្ញាតឱ្យប្រមូលផលតាមកម្រិតកំណត់នៃផែនការ និងតាមប្រភេទឈើដែលត្រូវសំរេចដោយ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៤ :** ការប្រមូលផលប្រភេទឈើម៉ៃសាក់ ប្រភេទឈើស្រល់ និងប្រភេទឈើផ្សេងទៀត ដែលបានធ្វើការដាំដុះជាចំការព្រៃដាំរបស់រដ្ឋ ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៥ :** ការកែច្នៃ ឬចាំងឈើហ៊ុបមូលទៅជាឈើហ៊ុបជ្រុងនៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ ហើយរាល់ឈើហ៊ុបជ្រុងទាំងនោះ ត្រូវបានចាត់ទុកជាឈើល្មើសច្បាប់ ។

**ប្រការ ៦ :** ក្នុងដំណើរការប្រមូលផល រាល់ឈើហ៊ុបមូលដែលមានអង្កត់ផ្ចិតក្រោមទំហំអប្បបរមាតាមប្រភេទឈើ ដូចមានចែងក្នុងឧបសម្ព័ន្ធទី I នៃប្រការ ២ ខាងលើ មានជាអាទិ៍ កំណាត់ឈើហ៊ុបដែលបានមកពីការបើកផ្លូវដឹកជញ្ជូន-អូសទាញ បានមកពីការដកហូតតាមបច្ចេកទេសរុក្ខវប្បកម្ម បាន់មកពីការដួលរំលំដោយប្រភេទឈើធំៗដួលសង្កត់ក្នុងពេលប្រមូលផល ឬ ក្នុងឧប្បទ្ទវហេតុផ្សេងៗទៀត ។ល។ ត្រូវមានកំណត់ហេតុច្បាស់លាស់ និងមានការឯកភាពរបស់នាយផ្នែករដ្ឋបាលព្រៃឈើសាមី ។

**ប្រការ ៧ :** ត្រូវបានចាត់ទុកជាប្រភេទឈើមានដោយកម្រ ចំពោះប្រភេទរុក្ខជាតិព្រៃឈើទាំងឡាយណាដែលមានអត្រារបាយទាប ការបន្តពូជក្នុងធម្មជាតិមានសក្តានុពលទាប កម្រជួបប្រទះក្នុងប្រព័ន្ធមជ្ឈដ្ឋាននៃព្រៃបំរុងទុកអចិន្ត្រៃយ៍ មានតម្លៃផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ច-សង្គម វប្បធម៌ និងអាចប្រឈមមុខចំពោះការគំរាមកំហែង ឬ ផុតពូជ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី II នៃប្រកាសនេះ ។

**ប្រការ ៨ :** ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី គឺសំដៅទៅលើដើមឈើផ្តល់ជ័រទឹកដែលធ្លាប់បាន និងកំពុងកាន់កាប់ ឬប្រើប្រាស់ជាលក្ខណៈប្រពៃណី ដោយប្រជាជនសហគមន៍មូលដ្ឋានក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី III នៃប្រកាសនេះ ។

**ប្រការ ៩ :** អាចអនុញ្ញាតឱ្យចោះយកជ័របាន ចំពោះដើមឈើទាលដែលដុះក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ លុះត្រាតែមានអង្កត់ផ្ចិតចាប់ពី ៤៥សម ឡើងទៅវាស់នៅត្រង់កំពស់ ១.៣០ម ពីដី ។

ការប្រមូលផលដើមឈើដែលប្រជាជនសហគមន៍មូលដ្ឋានចោះយកជ័រតាមប្រពៃណី នៅក្នុងព្រៃគុប ទោះជាដើមឈើទាលដែលមានអង្កត់ផ្ចិតចាប់ពី ១២០សម ឡើងទៅក៏ដោយ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការព្រមព្រៀង និង យល់ព្រមពីម្ចាស់ដើមឈើផ្តល់ជ័រនោះ ។

**ប្រការ ១០ :** ដើមឈើផ្តល់ជ័រមានតំលៃ គឺសំដៅលើប្រភេទដើមឈើដែលអាចផ្តល់ជ័រ ឬទ្រទ្រង់ជ័រល័ក្ខ ដែលមានតម្លៃផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ច-សង្គម និង វប្បធម៌ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី IV នៃប្រកាសនេះ ។

**ប្រការ ១១ :** ប្រភេទឈើទាំងឡាយណាដែលគ្មានចែងក្នុងបញ្ជីឈ្មោះកំណត់ក្នុងឧបសម្ព័ន្ធទី I, ទី II, ទី III, និងទី IV នៃប្រកាសនេះ រដ្ឋបាលព្រៃឈើត្រូវខិតខំស្រាវជ្រាវ សិក្សាបន្ថែម ដើម្បីស្នើសុំបញ្ចូលក្នុងតារាងចំណាត់ថ្នាក់ពាក់ព័ន្ធជាចាំបាច់ ។

ផល អនុផលព្រៃឈើទាំងអស់ ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី I, ទី II, ទី III, និងទី IV នៃប្រកាសនេះ អាចពិនិត្យកែប្រែឡើងវិញតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ចំពោះប្រភេទឈើទាំងឡាយណាដែលមិនមានចែងក្នុងតារាងឧបសម្ព័ន្ធទី I នៃប្រការ ២ ខាងលើនេះ ត្រូវបានចាត់ទុកជាប្រភេទឈើមិនទាន់ចាត់ថ្នាក់ ។

**ប្រការ ១២ :** ជនណាប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ ។

**ប្រការ ១៣ :** ប្រកាស ឬសេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៤ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និងប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី.១៤....ខែ.កុម្ភៈ....ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ១៤
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី I ភ្ជាប់ប្រកាសលេខ .០៨៥............ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

## ប្រភេទឈើដាច់ក្នុងលំដាប់ថ្នាក់ និង ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ

| ល.រ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | | ទំហំអប្បបរមា អនុញ្ញាតឱ្យកាប់រំលំ |
|---|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ | |
| **ឈើប្រណីត** | | | | | | |
| ១ | 0.1 | អង្កាញ់ | Angkanh / Cassia | Cassia siamea, Lam. | Caesalpiniaceae | ០.៤៥ ម |
| ២ | 0.2 | អង្កត់ខ្មៅ | Angkat khmau / Kayu Malam / Ebony | Diospyros bejaudi, Lec. | Ebenaceae | ០.៤៥ ម |
| ៣ | 0.3 | បេង | Beng / Afzelia | Afzelia xylocarpa, (Kurz) Craib | Caesalpiniaceae | ០.៤៥ ម |
| ៤ | 0.4 | ឈើខ្មៅ | Chhoeu khmau / Kayu Malam / Ebony | Diospyros sp. | Ebenaceae | ០.៤៥ ម |
| ៥ | 0.5 | ជើងចាប | Choeng chap / Mempisang / Karai | Dasymachalon lomentaceum, Fin.& Gagn. | Annonaceae | ០.៤៥ ម |
| ៦ | 0.6 | ច្រេស | Chres / Albizia | Albizia lebbeck, (L.) Benth | Mimosaceae | ០.៤៥ ម |
| ៧ | 0.7 | ហៃសាន ឬ ចាន់ស | Haisan / Chansor | Cassia garretiana, Craib | Caesalpiniaceae | ០.៤៥ ម |
| ៨ | 0.8 | ហ៊ុនដាង ឬ ម្រះព្រៅភ្នំ | Hundang / Mreah prau phnom / Cedar white | Dysoxylum loureiri, Pierre | Meliaceae | ០.៤៥ ម |
| ៩ | 0.9 | ក្រញូង | Kranhung / Tulipwood / Burma | Dalbergia cochinchinensis, Pierre | Papilionaceae | ០.៤៥ ម |
| ១០ | 0.10 | គ្រើល | Kroeul / Rengas / Machang | Melanorrhea laccifera, Pierre | Anacardiaceae | ០.៤៥ ម |
| ១១ | 0.11 | នាងនួន ឬ ណាំង | Neang noun / Camiai / Tulipwood / Burma | Dalbergia bariensis, Pierre | Papilionaceae | ០.៤៥ ម |
| ១២ | 0.12 | តាត្រាវ | Tatrao / Tembusu / Anan | Fagraea fragrans, Roxb. | Loganiaceae | ០.៤៥ ម |
| ១៣ | 0.13 | ធ្នង់ | Thnong / Padauk | Pterocarpus pedatus, Pierre | Papilionaceae | ០.៤៥ ម |
| ១៤ | 0.14 | ត្រយឹង | Trayoeung / Kayu Malam / Ebony | Diospyros helferi, C.B.Clarke | Ebenaceae | ០.៤៥ ម |
| **ឈើលេខ ១** | | | | | | |
| ១៥ | 1.1 | បូសនាគ | Bosneak / Penaga / Mesua | Mesua ferrea, L. | Guttiferae | ០.៣០ម |
| ១៦ | 1.2 | ស្ដី | Sdey | Crudia chrysantha, (Pierre) Schum. | Caesalpiniaceae | ០.៣០ម |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | 1.3 | សំព័រ | Sompor / Keledang | Artocarpus sempervirens | Moraceae | ០,៣៥ម |
| ១៨ | 1.4 | ស្រឡៅ ឬ ឥន្ទនេល | Sralao / Enthenel / Peyinma / Benteak | Lagerstroemia sp. | Lythraceae | ០,៣៥ម |
| ១៩ | 1.5 | ត្រសេក ឬ ត្រាំកង់ | Trasek / Tramkang | Peltophorum ferrugineum, Benth. | Caesalpiniaceae | ០,៣៥ម |
| ២០ | 1.6 | ទ្រាល | Treal | Peltophorum dasyrachis(Miq.) Kurz | Caesalpiniaceae | ០,៣៥ម |
| ២១ | 1.7 | បេឡឺយ | Beleuy / Medang | Litsea vang, H.Lec. | Lauraceae | ០,៤៥ម |
| ២២ | 1.8 | ដូនចែម ឬ បីសន្លឹក | Dauncham / Beisanleuk / Mengkulang | Tarrietia javanica, Bl. | Sterculiaceae | ០,៤៥ម |
| ២៣ | 1.9 | កែស | Kes / Nyatou / Bitis | Manilkara hexandra, (Roxb.) Dub. | Sapotaceae | ០,៤៥ម |
| ២៤ | 1.10 | កកោះ | Kakah / Sepetir | Sindora cochinchinensis, Baill. | Caesalpiniaceae | ០,៤៥ម |
| ២៥ | 1.11 | ក្រឡាញ់ | Kralanh / Keranji | Dialium cochinchinensis, Pierre | Caesalpiniaceae | ០,៤៥ម |
| ២៦ | 1.12 | ម៉ៃសាក់ | Maisak / Teak | Tectona grandis, L.f. | Verbenaceae | ០,៤៥ម |
| ២៧ | 1.13 | ផ្ចឹក | Phchek / Meranti / Balau | Shorea obtusa, Woll. | Dipterocarpaceae | ០,៤៥ម |
| ២៨ | 1.14 | ផ្កាយព្រឹក | Phkay preuk / Ipil | Afzelia bijuga, (Colebr.) A.Gray | Caesalpiniaceae | ០,៤៥ម |
| ២៩ | 1.15 | ពពូល ឬ ភ្នែល | Popoul / Phnel | Vitex sp. | Verbenaceae | ០,៤៥ម |
| ៣០ | 1.16 | រាំងភ្នំ | Raing phnom / Meranti | Shorea siamensis, Miq. | Dipterocarpaceae | ០,៤៥ម |
| ៣១ | 1.17 | សង្កួតថ្មាត | Sangkuothmat | Stereospermum chelonoides (non L.Dop) | Bignoniaceae | ០,៤៥ម |
| ៣២ | 1.18 | សុក្រម | Sokram / Pyinkado | Xylia dolabriformis, Benth. | Mimosaceae | ០,៤៥ម |
| ៣៣ | 1.19 | ស្មែ | Sme / Poga | Ceriops roxburghiana, Arn. | Rhizophoraceae | ០,៤៥ម |
| ៣៤ | 1.20 | ឈ្លីក | Chhlik / Ketapang / Laurel | Terminalia alata, F. Heyne ex Roth | Combretaceae | ០,៤៥ម |
| ៣៥ | 1.21 | គគីរដែក | Koki dek / Giam / Merawan | Hopea helferi, Brandis | Dipterocarpaceae | ០,៥០ម |
| ៣៦ | 1.22 | គគីរម្សៅ | Koki masau / Giam / Merawan | Hopea odorata, Roxb. | Dipterocarpaceae | ០,៥០ម |
| ៣៧ | 1.23 | គគីរថ្ម | Koki thmor / Giam / Merawan | Hopea ferrea, Pierre | Dipterocarpaceae | ០,៥០ម |
| ៣៨ | 1.24 | ពពេល | Popel / Giam / Merawan | Shorea roxburghii, G.Don. | Dipterocarpaceae | ០,៥០ម |
| ៣៩ | 1.25 | វល្លិយោង | Voryaung / Chicrassy | Chukrasia tabularis, Ant. Juss. | Meliaceae | ០,៦០ម |

| ឈើលេខ ២ | | | | | | |
|---|---|---|---|---|---|---|
| ៤០ | 2.1 | ឆាំឆា | Chhamchha / Cedar | Toona febrifuga, M.Roem | Meliaceae | ០.៣០ម |
| ៤១ | 2.2 | ច្រម៉ាស់ | Chramas / Resak | Vatica astrotricha, Dyer. | Dipterocarpaceae | ០.៣០ម |
| ៤២ | 2.3 | ស្រគុំ | Srakum / Nyatoh / Payena | Payena elliptica, Lecomte | Sapotaceae | ០.៣០ម |
| ៤៣ | 2.4 | ទទឹមព្រៃ | Totem prey | | | ០.៣០ម |
| ៤៤ | 2.5 | ត្រឡាត់ | Tralat / Resak | Vatica philastreana, Pierre | Dipterocarpaceae | ០.៣០ម |
| ៤៥ | 2.6 | អាទិត្យ ឬ នាងផ្អែក | Atith / Medang | Hassia cuneata, Blume | Lauraceae | ០.៤៥ម |
| ៤៦ | 2.7 | ខ្ជូវ,កំលេង ឬ ផ្ចឹកឱដំ | Khchov / Komleng / Phchek audom / Meranti | Shorea thorelli, Pierre | Dipterocarpaceae | ០.៤៥ម |
| ៤៧ | 2.8 | គគីរខ្សាច់ | Koki khsach / Giam | Hopea pierrei, Pierre | Dipterocarpaceae | ០.៤៥ម |
| ៤៨ | 2.9 | គគីរភ្នង ឬ កំញាន | Koki phnong / Kom nhan / Meranti | Shorea hypochra, Hance | Dipterocarpaceae | ០.៤៥ម |
| ៤៩ | 2.10 | លំបោ | Lumbor / Meranti | Shorea. farinosa, C.Fisch. | Dipterocarpaceae | ០.៤៥ម |
| ៥០ | 2.11 | ផ្ដៀក | Phdiek / Mersawa / Krabak | Anisoptera costata, Korth. | Dipterocarpaceae | ០.៤៥ម |
| ៥១ | 2.12 | ស្រល់ | Sral / Pine | Pinus merkusii, Jungh & de Vries | Pinaceae | ០.៤៥ម |
| ៥២ | 2.13 | ស្រូលស | Sraul sar / Podo / Sempilor | Podocarpus imbricatus, Blume | Podocarpaceae | ០.៤៥ម |
| ៥៣ | 2.14 | ស្រូលក្រហម | Sraul kraham / Podo / Sempilor | Dacrydium elatum, Wall. ex Hook. | Podocarpaceae | ០.៤៥ម |
| ៥៤ | 2.15 | ត្បែង | Thbeng / Keruing | Dipterocarpus obtusifolius, Teysm. | Dipterocarpaceae | ០.៤៥ម |
| ៥៥ | 2.16 | ខ្វាវ | Khvao / Haldu | Adina cordifolia, Hook.f. | Rubiaceae | ០.៤៥ម |
| ៥៦ | 2.17 | ខ្លុង | Khlong / Keruing | Dipterocarpus tuberculatus, Roxb. | Dipterocarpaceae | ០.៥០ម |
| ៥៧ | 2.18 | ត្រាច | Trach / Keruing | Dipterocarpus intricatus, Dyer. | Dipterocarpaceae | ០.៥០ម |
| ៥៨ | 2.19 | ឈើទាលបង្គួយ ឬ ឈើទាលនាងដែង | Chhoeuteal / Keruing | Dipterocarpus costatus, Gaertn. | Dipterocarpaceae | ០.៦០ម |
| ៥៩ | 2.20 | ឈើទាលធ្ង | Chhoeuteal / Keruing | Dipterocarpus dyeri, Pierre | Dipterocarpaceae | ០.៦០ម |

| | | | | | | |
|---|---|---|---|---|---|---|
| ៦០ | 2.21 | ឈើទាលខ្មៅ ឬឈើទាលទឹក ឬ ឈើទាលបាយ | Chhoeuteal / Keruing | Dipterocarpus alatus, Roxb. | Dipterocarpaceae | 0.៦០ម |
| ៦១ | 2.22 | ឈើទាលប្រេង | Chhoeuteal / Keruing | Dipterocarpus jourdainii, Pierre | Dipterocarpaceae | 0.៦០ម |
| ៦២ | 2.23 | ជ័រចុង | Chhor chong / Meranti | Shorea vulgaris, Pierre | Dipterocarpaceae | 0.៦០ម |
| | | | **ឈើលេខ ៣** | | | |
| ៦៣ | 3.1 | ចេកទុំ | Chektum / Medang | Cinnamomum litsaefolium, Thw. | Lauraceae | 0.៣០ម |
| ៦៤ | 3.2 | ក្តុល | Kdol | Sarcocephalus cordatus, Mig. | Rubiaceae | 0.៣០ម |
| ៦៥ | 3.3 | ខ្ទឹង | Khchung / Bintangor / Poon | Calophyllum inophyllum, L. | Gutttiferae | 0.៣០ម |
| ៦៦ | 3.4 | កោងកាង | Kongkang / Poga | Rhizophora mucronata, Poir. | Rhizophoraceae | 0.៣០ម |
| ៦៧ | 3.5 | ក្រពៅ | Krabau | Hydnocarpus anthelmintica, Pierre | Flacourtiaceae | 0.៣០ម |
| ៦៨ | 3.6 | ក្រាយស | Kray sar / Kokko | Albizia thorelii, Pierre | Mimosaceae | 0.៣០ម |
| ៦៩ | 3.7 | ក្រាស | Kras | Quassia Harmandiana, (Pierre) Noot. | Simaroubaceae | 0.៣០ម |
| ៧០ | 3.8 | ល្ងៀង | Longeang | Cratoxylon prunifolium, Dyer. | Hypericaceae | 0.៣០ម |
| ៧១ | 3.9 | ផ្ទុង | Phaong / Bintangor / Poon | Callophyllum sp. | Guttiferae | 0.៣០ម |
| ៧២ | 3.10 | ព្រីង "គ្រប់បែប" | Pring / Kelat | Eugenia spp. | Myrtaceae | 0.៣០ម |
| ៧៣ | 3.11 | ព្រូស | Prous / Bintangor / Poon | Gercinia ferrea, Pierre | Guttiferae | 0.៣០ម |
| ៧៤ | 3.12 | ស្មាច់ | Smach / Kelat | Melaleuca leucadendron, L. | Myrtaceae | 0.៣០ម |
| ៧៥ | 3.13 | គ្រប់ទុំ | Troptum | Xanthophyllum Colubrinum, Gagn. | Xanthophyllaceae | 0.៣០ម |
| ៧៦ | 3.14 | បាយពូវាំង | Baypouvang / Katon | Aglaia spectabilis, S.K. Jain & Benn | Meliaceae | 0.៣០ម |
| ៧៧ | 3.15 | អាទាំង ឬ រទាំង | Ataing | Homalium brevidens, Gagnep | Flacourtiaceae | 0.៣៥ម |
| ៧៨ | 3.16 | ចន្ទន៍ក្រស្នា | Chankrasna / Sandal | Aquilaria crassna, Pierre | Thymeleaceae | 0.៣៥ម |
| ៧៩ | 3.17 | បង្កោ | Bangkow / Segera | Aglaia cambodiana, Pierre | Meliaceae | 0.៣៥ម |
| ៨០ | 3.18 | ប្រាំដំឡឹង | Pramdamloeng / Ketepang / Chuglam | Terminalia mucronata, Graib et Huth | Combretaceae | 0.៤០ម |

| | | | | | | |
|---|---|---|---|---|---|---|
| ៨១ | 3.19 | ចាន់ទំពាំង | Chantampang / Kelumpang | Sterculia alata, Roxb. | Sterculiaceae | 0.៤៥ម |
| ៨២ | 3.20 | ចង្អូរថ្នាត | Changourthmat | Vitex pinnata, L. | Verbenaceae | 0.៤៥ម |
| ៨៣ | 3.21 | កណ្ដោល | Kandaul | Careya sphaerica, Pierre | Moraceae | 0.៤៥ម |
| ៨៤ | 3.22 | ខ្នុរព្រៃ | Khnorpreiy / Keledan | Artocarpus asperula, Gagn. | Moraceae | 0.៤៥ម |
| ៨៥ | 3.23 | កំពីងរាជ | Kampingreach | Sandoricum indicum, Cav. | Meliaceae | 0.៤៥ម |
| ៨៦ | 3.24 | ស្មាក្របី | Smakarbei / Penarahan | Knema corticosa, Lour. | Myristicaceae | 0.៤៥ម |
| ៨៧ | 3.25 | ស្វាយព្រៃ | Svayprei / Machang | Mangifera duperreana, Pierre | Anacardiaceae | 0.៤៥ម |
| ៨៨ | 3.26 | ត្ង | Taour / Ketapan | Terminalia cambodiana, Gagn. | Combretaceae | 0.៤៥ម |
| ៨៩ | 3.27 | ធ្លក | Thlork | Parinarium annamensis, Hance | Rosaceae | 0.៤៥ម |
| ៩០ | 3.28 | ត្រមូង | Tramoung | Garcinia oliveri, Pierre | Guttiferae | 0.៤៥ម |
| ៩១ | 3.29 | ត្រមែង | Trameng / Poga | Carallia lucida, Roxb. | Rhizophoraceae | 0.៤៥ម |
| ៩២ | 3.30 | ស្វាយចំរៀង | Svaychamreang / Merbauh | Swintonia pierrei, Hance | Anacardiaceae | 0.៤៥ម |
| ៩៣ | 3.31 | សំពង់ | Sampong | Tetrameles nudiflora, R.Br. | Datiscaceae | 0.៦០ម |

## ឧបសម្ព័ន្ធទី II ភ្ជាប់ប្រកាសលេខ ...[illegible]... ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

### ប្រភេទឈើមានដោយកម្រ

| លរ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | |
|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ |
| ១ | 0.1 | អង្កាញ់ | Angkanh / Cassia | Cassia siamca, Lam. | Cacsalpiniaccac |
| ២ | 0.2 | អង្កត់ខ្មៅ | Angkat khmau / Kayu Malam / Ebony | Diospyros bejaudi, Lcc. | Ebenaccac |
| ៣ | 0.3 | បេង | Beng / Afzelia | Afzelia xylocarpa, (Kurz) Craib | Cacsalpiniaccac |
| ៤ | 0.4 | ឈើខ្មៅ | Chhoeu khmau / Kayu Malam / Ebony | Diospyros sp. | Ebenaccac |
| ៥ | 0.5 | ជើងចាប | Choeng chap / Mempisang / Karai | Dasymachalon lomentaceum, Fin.& Gagn. | Annonaccac |
| ៦ | 0.6 | ច្រេស | Chres / Albizia | Albizia lebbeck, (L.) Benth | Mimosaccac |
| ៧ | 0.7 | ហៃសាន ឬ ចាន់ស | Haisan / Chansor | Cassia garretiana, Craib | Cacsalpiniaceae |
| ៨ | 0.8 | ហ៊ុនដាង ឬ ម្រះព្រៅភ្នំ | Hundang / Mreah prau phnom / Cedar white | Dysoxylum loureiri, Pierre | Meliaccac |
| ៩ | 0.9 | ក្រញូង | Kranhung / Tulipwood / Burma | Dalbergia cochinchinensis, Pierre | Papilionaccac |
| ១០ | 0.10 | គ្រើល | Krocul / Rengas / Machang | Melanorrhoea laccifera, Pierre | Anacardiaccac |
| ១១ | 0.11 | នាងនួន ឬ ណាំង | Neang noun / Camlai / Tulipwood / Burma | Dalbergia bariensis, Pierre | Papilionaceae |
| ១២ | 0.12 | តាត្រាវ | Tatrao / Tembusu / Anan | Fagraca fragrans, Roxb. | Loganiaccac |
| ១៣ | 0.13 | ធ្នង់ | Thnong / Padauk | Pterocarpus pedatus, Pierre | Papilionaccac |
| ១៤ | 0.14 | ត្រយឹង | Trayocung / Kayu Malam / Ebony | Diospyros helferi, C.B.Clarke | Ebenaccac |
| ១៥ | 2.12 | ស្រល់ | Sral / Pine | Pinus merkusii, Jungh & de Vries | Pinaccac |

**ឧបសម្ព័ន្ធទី III ភ្ជាប់ប្រកាសលេខ ....០.៧.៨.ប្រ.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥**

**ប្រភេទឈើដែលប្រថាប់មូលដ្ឋានបោះយកជ័រតាមប្រពៃណី**

| លរ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | |
|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ |
| ១ | 1.13 | ផ្ចឹក | Phchek / Meranti / Balau | Shorea obtusa, Woll. | Dipterocarpaceae |
| ២ | 1.24 | ពពេល | Popel / Giam / Merawan | Shorea roxburghii, G.Don. | Dipterocarpaceae |
| ៣ | 2.2 | ច្រមាស់ | Chramas / Resak | Vatica astrotricha, Dyer. | Dipterocarpaceae |
| ៤ | 2.15 | ត្បែង | Thbeng / Keruing | Dipterocarpus obtusifolius, Teysm. | Dipterocarpaceae |
| ៥ | 2.17 | ខ្លុង | Khlong / Keruing | Dipterocarpus tuberculatus, Roxb. | Dipterocarpaceae |
| ៦ | 2.18 | ត្រាច | Trach / Keruing | Dipterocarpus intricatus, Dyer. | Dipterocarpaceae |
| ៧ | 2.19 | ឈើទាលបង្គួយ ឬ ឈើទាលនាងដែង | Chhoeuteal / Keruing | Dipterocarpus costatus, Gaertn. | Dipterocarpaceae |
| ៨ | 2.20 | ឈើទាលធ្ង | Chhoeuteal / Keruing | Dipterocarpus dyeri, Pierre | Dipterocarpaceae |
| ៩ | 2.21 | ឈើទាលម្សៅ ឬ ឈើទាលទឹក ឬ ឈើទាលបាយ | Chhoeuteal / Keruing | Dipterocarpus alatus, Roxb. | Dipterocarpaceae |
| ១០ | 2.22 | ឈើទាលប្រេង | Chhoeuteal / Keruing | Dipterocarpus jourdainii, Pierre | Dipterocarpaceae |
| ១១ | 2.23 | ជ័រចុង | Chhor chong / Meranti | Shorea vulgaris, Pierre | Dipterocarpaceae |

## ឧបសម្ព័ន្ធទី IV ភ្ជាប់ប្រកាសលេខ .០៧៥..ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥
## ប្រភេទឈើផ្តល់ជ័រមានតម្លៃ និង ធ្នូធ្នង់ជំរើគូ

| លរ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | |
|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ |
| ១ | 2.7 | ខ្ជាវ . កំលែង ឬ ផ្ចឹកឧត្តម | Khchov / Komleng / Phchek audom / Meranti | Shorea thorelli, Pierre | Dipterocarpaceae |
| ២ | 3.16 | ចន្ទន៍ក្រស្នា | Chankrasna / Sandal | Aquilaria crassna, Pierre | Thymelaeaceae |
| ៣ | NC | ដើមនី | Doeumny | Palaquium obovatum, (Griff.) Engler | Sapotaceae |
| ៤ | NC | រង | Rung | Garcinia handburyi, Hook. f. | Guttiferae |
| ៥ | NC | ជ្រៃ | Chrey | Ficus sp. | Moraceae |
| ៦ | NC | សង្កែ | Sangke | Combretum quadrangulare, Kurz. | Combretaceae |
| ៧ | NC | ស្នួល | Snuol | Dalbergia nigressens, Kurz. | Papilionaceae |
| ៨ | NC | ត្រាង | Trang | Ficus altissima, Blume | Moraceae |
| ៩ | NC | ពង្រ | Pungro | Schleicheria trijuga, Willd. | Sapindaceae |
| ១០ | NC | សាលព្រឹក្ស | Salproeuk | Couroupita guianensis, Aublet | Lecythidaceae |